# របាយការណ៍ប្រចាំឆ្នាំ ២០០៤




# CSARO Annual Review 2004

# សារពីនាយកកម្មវិធីអង្គការស្ការ៉ូ

២០០៤ គឺជាឆ្នាំមួយពោរពេញទៅដោយកាលៈទេសៈ និង ការពុះពារជាច្រើនសំរាប់អង្គការ(ស្ការ៉ូ)។ យើងមានក្ដីសោមនស្សរីករាយ ស្វាគមន៍បុគ្គលិកថ្មី ចំនួន ៦រូប មកក្នុងក្រុមការងាររបស់យើង ហើយទទួលបាននូវគំនិត និង បទពិសោធន៏ថ្មីៗជាច្រើន។

ការដាក់អោយអនុវត្តនូវផែនការយុទ្ធសាស្ត្រថ្មី មានរយៈពេលបីឆ្នាំរបស់អង្គការ(ស្ការ៉ូ) ធ្វើអោយមានការរៀបរចនាសម្ព័ន្ធឡើងវិញនូវកម្មវិធីខ្លះ ដើម្បីអោយកាន់តែមានប្រសិទ្ធិភាព និង ប្រើប្រាស់កាន់តែប្រសើរនូវធនធានរបស់អង្គការ។ ពេលបច្ចុប្បន្ននេះ អង្គការ(ស្ការ៉ូ) មានមណ្ឌលធនធានសហគមន៏ថ្មីមួយ ដែលទទួលខុសត្រូវលើយុទ្ធនាការអប់រំសាធារណៈ ផលិតសម្ភារៈអប់រំ បូកបញ្ចូលទាំងសកម្មភាពគួរអោយមានចំណាប់អារម្មណ៏ថ្មីៗខ្លះទៀត រួមទាំងការបង្កើតនូវបណ្ណាល័យធនធនសហគមន៏មួយផងដែរ។ ដើម្បីធានានូវវិធីសាស្ត្រងាយស្រួលមួយ ចំពោះការអភិវឌ្ឍធនធានមនុស្ស (សំរាប់បុគ្គលិក និងសមាជិកក្រុមគោលដៅ អង្គការ(ស្ការ៉ូ) ក៏បានបង្កើតនូវកម្មវិធីអភិវឌ្ឍន៏ស្ថាប័នថ្មីមួយ ដែលទទួលខុសត្រូវចំពោះការវាយតំលៃប៉ាន់ប្រមាណ លើតំរូវការបណ្តុះបណ្តាល, ការរៀបចំកម្មវិធីបណ្តុះបណ្តាលនានា, ការធ្វើទស្សនះកិច្ចសិក្សា, របៀបពិនិត្យតាមដានលើការបំពេញការងារ និង ភារកិច្ច ដ៏ទៃទៀត។

កម្មវិធីខ្លះដែលមានពីមុនរបស់អង្គការ(ស្ការ៉ូ) ត្រូវបានពង្រីក និង បង្កើនថែមទៀត។ ឥឡូវនេះ កម្មវិធីអប់រំផ្សព្វផ្សាយចល័តមានរថយន្តក្រុងថ្មីមួយ ដែលបង្កអោយមានភាពងាយស្រួលដល់ក្រុមការងារធ្វើការបង្រៀននៅតាមចិញ្ចើមផ្លូវ ផ្ដល់ការថែរក្សាបឋម និង ពិគ្រោះយោបល់ ជាមួយក្មេងៗរើស(អេតចាយ) ទាំងនៅពេលថ្ងៃក្ដៅ និង ពេលភ្លៀងធ្លាក់។ ក្រុមការងារអប់រំផ្សព្វផ្សាយចល័តបានពង្រីកតំបន់ណាត់ជួបអ្នករើស(អេតចាយ) យ៉ាង ទ្យេងទាត់ មានចំនួន ១៧ កន្លែង ហើយពេលបច្ចុប្បន្ននេះ ក្នុងមួយសប្តាហ៏ៗ ធ្វើការជាមួយកុមារអ្នករើស(អេតចាយ)ចំនួន ៣១៨ នាក់។ ប្រព័ន្ធពិនិត្យ តាមដានសាកល្បងថ្មីមួយ ពីភាពរីកចំរើនរបស់ក្មេងៗ ហើយនិងការកែតំរង់កម្មវិធី ទៅតាមសេចក្ដីត្រូវការរបស់ក្រុមគោលដៅ។

នៅក្នុងដើមឆ្នាំ ២០០៤ ក្រុមជួយខ្លួនឯងអ្នករើស(អេតចាយ) ដែលគាំទ្រដោយអង្គការ(ស្ការ៉ូ) បានផ្ដើមកម្មវិធីប្រមូលសំរាមថ្មីមួយ ដែលឧបត្ថម្ភពីគំរោង JFPR នៅក្រោមអាជ្ញាធរក្រុងភ្នំពេញ។ មណ្ឌលកែច្នៃសំរាមថ្មីមួយទៀត ត្រូវបានរៀបចំឡើងនៅក្នុងគំរោងនោះដែរ។ ប៉ុន្តែជា អកុសលនៅក្នុងខែ កក្កដា ក្រុមប្រឹក្សាភិបាលរបស់អង្គការ(ស្ការ៉ូ) បានធ្វើការសំរេចចិត្តថា វាជាការចាំបាច់ក្នុងការដកខ្លួនចេញពីគំរោងនោះ បន្ទាប់ពីមានភាពលំបាកដែលមានរយៈពេលរាប់ខែ ជាមួយថ្នាក់គ្រប់គ្រងក្រុង លើថវិកាដំណាក់កាលលើកទីពីរ។ កម្មវិធីគ្រប់គ្រងសំណល់ អង្គការ(ស្ការ៉ូ)ត្រូវបានធ្វើការពិនិត្យឡើងវិញថែមទៀត នៅពេលដែលសាលាក្រុងបានផ្លាស់ប្តូរគោលនយោបាយគ្រប់គ្រងសំណល់របស់ខ្លួន និង ធ្វើការផ្ទេរការប្រមូលសំរាមនៅក្នុង តំបន់ NIP"ដែលជាកន្លែង ក្រុមជួយខ្លួនឯងអ្នករើស(អេតចាយ) បានធ្វើប្រតិបត្តិការតាំងពីឆ្នាំ ២០០១ មកម្ល៉េះ"។ លទ្ធផលនៃការផ្លាស់ប្តូរ គោលនយោបាយផ្សេងៗទៀត ដែលមានការទាក់ទង និងការងារប្រមូលសំរាម របស់ក្រុមជួយខ្លួនឯងអ្នករើស (អេតចាយ)ទាំងអស់ ក៏ត្រូវបានផ្អាក ហើយសមាជិកក្រុមជួយខ្លួនឯងអ្នករើស(អេតចាយ)ច្រើនជាង ៥៨នាក់ បានបាត់បង់ការងារធ្វើ។ តាំងពីពេលពេលនោះមក, ក្រុមជួយខ្លួនឯងអ្នករើស(អេតចាយ) មានទំហំតូចជាងមុនពួកគេមានលទ្ធភាពចាប់ផ្ដើមការងារប្រមូលសំភារៈកែច្នៃ និង ធ្វើជីកំប៉ុស្ត នៅឯមណ្ឌលមានទំហំធ្លាក់ចុះយ៉ាងច្រើន។

បទពិសោធន៏នានា នៅឆ្នាំ ២០០៤ បានជួយធ្វើអោយអង្គការ(ស្ការ៉ូ) ក្លាយជាអង្គការមួយមានបទពិសោធន៏ច្រើនឡើង និង មានប្រសិទ្ធភាពជាងមុន។ យើងបន្តការងារដ៏សំខាន់នេះ នៅខាងមុខដើម្បីធ្វើអោយបរិស្ថានមានភាពប្រសើរឡើង ជាមួយនឹងដំណោះស្រាយ ធ្វើការអភិវឌ្ឍន៏សង្គម និង សេដ្ឋកិច្ចរបស់អ្នករើសសំរាម និង សហគមន៏ក្រីក្រនានាដែលរស់នៅតាមទីក្រុង។

**ហេង យ៉ុនគូវ៉ា**

នាយកកម្មវិធី អង្គការកែច្នៃ និង អនាម័យសហគមន៏ (ស្ការ៉ូ)

# Director's Message





2004 was a year of opportunities and challenges for CSARO. We were happy to welcome six new staff members to our team and are enjoying the influx of new ideas and experience.

Implementation of CSARO's new three-year strategic plan meant restructuring some of the programs to make the work more efficient and better use the organizations resources. CSARO now has a new Community Resources Center responsible for public education campaigns, production of educational materials, plus some exciting new activities including the creation of a community resource library. To ensure a consistent approach to human resource development (for both staff and target group members), CSARO also created a new Institutional Development Program responsible for training-needs assessment, design of training programs, exposure trips, performance monitoring and other tasks.

Some of CSARO's older programs have also been expanded and improved. Our Mobile Outreach Education Program now has a new bus with a collapsible sunshade that enables the team to provide curbside lessons, first aid and counseling to waste picker children in both sunny and rainy weather. The team has expanded coverage to 17 regular contact points and now reaches an average of 318 children per week. A new testing and monitoring system helps track children's progress and to tailor the program to the target group's needs.

Early in 2004, CSARO supported Waste Picker Self-Help Groups (SHGs) began a new waste collection program funded by the JFPR project under the municipal government of Phnom Penh. A new recycling center was also planned under the same project. Unfortunately, in July CSARO's board of directors decided it was necessary to pull out of the project, after several months of difficulties with the city managers over the second phase budget. CSARO's solid waste management program had to make further revisions when the Municipality changed its waste management policy and transferred responsibility for waste collection in the NIP area (where SHGs had operated since 2001). As a result of these and other policy changes, all SHG waste collection contracts were halted and more than 58 SHG members lost their jobs. Since the changes, a smaller group was able to restart recycling and composting operations at the Center on a much reduced scale.

The experiences of 2004 have helped make CSARO a stronger, more effective organization. We look forward to continuing this important work of improving the environment while addressing the social and economic development of waste pickers and urban poor communities.

Heng Yon Kora, Program Director
Community Sanitation and Recycling Organization

# ប្រវត្តិរបស់អង្គការស្តារ៉ូ

អង្គការកែច្នៃ និង អនាម័យសហគមន៏( ស្តារ៉ូ) គឺជាអង្គការមិនមែនរដ្ឋាភិបា ល (NGO) កម្ពុជាមួយ ដែលបង្កើតឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដោយក្រុមមួយនៃអ្នកធ្វើការផ្នែកអភិវឌ្ឍន៏ ដែលមានការ-តាំងចិត្តក្នុងការ ធ្វើអោយបរិស្ថាន និង ស្ថានភាពរស់នៅរបស់ជនក្រីក្រក្នុងទីក្រុង នៅប្រ ទេសកម្ពុជាអោយមានភាពប្រសើរឡើង ។ អង្គការ( ស្តារ៉ូ) ជាអ្នកនាំមុខគេ ក្នុងការប្រើប្រាស់នូវរបៀបចូលរួមមួយ ដើម្បីធ្វើអោយប្រសើរដល់ស្ថាន ភាពនានា នៅក្នុងតំបន់ដែលគេមិនបានយកចិត្តទុកដាក់ និង តំបន់ដែលមិន មានការបំរើសេវា ដែលទីនោះហើយ ជាកន្លែងដែលអ្នកក្រីក្រទីក្រុងរស់នៅ ។ អង្គការ( ស្តារ៉ូ) ផ្តោតការងារពិសេសធ្វើអោយមានភាព ប្រសើរឡើង ដល់ស្ថានភាពរស់នៅ និង ការងាររបស់មនុស្សពេញវ័យ និង កុមាររើស (អេតចាយ) ចំនួនរាប់ពាន់នាក់ ដែលកំពង់រើសសំរាមសំរាប់ចិញ្ចឹម ជីវិតរស់នៅក្នុងទីក្រុងភ្នំពេញ ។

## ទស្សនៈអង្គការស្តារ៉ូ

សហគមន៏នានានៅក្នុងទីក្រុង ជាកន្លែងដែលប្រជាពលរដ្ឋ និង អ្នករើសសំរាម( អេតចាយ) ធ្វើការងារសហការជាមួយគ្នា ដើម្បីតំបន់សហគមន៏កខ្វក់ ផ្លាស់ប្តូរទៅជាតំបន់បរិស្ថានស្អាត, សុវត្ថិភាព និង មានសុខ ភាពល្អ ដើម្បីរស់នៅ ។ អ្នករើសសំរាមអេតចាយ-ទាំអស់ចេះធ្វើការរួម គ្នា ដើម្បីកែរលំអរស្ថានភាព សង្គម និង សេ-ដ្ឋកិច្ចផ្ទាល់របស់ក្រុមពួកគេកាន់តែប្រសើរឡើង ។

## បេសកកម្មអង្គការស្តារ៉ូ

លើកកំពស់សមត្ថភាពប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងដើម្បីធ្វើអោយបរិស្ថានសង្គម និង ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេមានភាពកាន់តែល្អប្រសើរឡើង ។

## គោលដៅអង្គការ( ស្តារ៉ូ)

១. ចូលរួមចំណែកជួយប្រជាពលរដ្ឋក្រីក្រ ដើម្បីធ្វើអោយប្រសើរផ្នែកហេដ្ឋារចនាសម្ព័ន្ធ, គ្រប់គ្រងកាកសំណល់ និង ប្រពន្ធ័ផ្សព្វផ្សាយពតិមានអនាម័យបរិស្ថាននៅតាមសហគមន៏របស់ពួកគេអោយបានល្អប្រសើរឡើង ។

២. ចូលរួមចំណែកជួយបង្កើនមុខជំនាញដល់ក្រុមអ្នករើសសំរាម (អេតចាយ) នៅក្នុងទីក្រុងអោយមានស្ថានភាព សង្គម និង សេដ្ឋកិច្ចគ្រួសារពួកគេល្អជាងមុនដោយធ្វើការជួយខ្លួនឯង ។

៣. ចូលរួមចំណែកជួយស្ថាបនាសមត្ថភាពដល់អ្នកសហគមន៏ និង អ្នករើសសំរាមអោយចេះធ្វើការអភិវឌ្ឍន៏ដោយខ្លួនឯង( សំរាប់និរន្តរភាពមួយពេលអនាគត) ។

៤. ពង្រឹងសមត្ថភាពដល់បុគ្គលិកទាំងអស់របស់អង្គការ( ស្តារ៉ូ) ដើម្បីកម្មវិធីការងារកាន់តែមានប្រសិទ្ធិភាពល្អប្រសើរ ។

## កម្មវិធីអង្គការស្តារ៉ូ

បន្ទាប់ពីការបញ្ចប់ផែនការយុទ្ធសាស្ត្រថ្មីមួយ សំរាប់រយៈពេល បី ឆ្នាំ (២០០៤-២០០៧) ក្នុងខែ កក្កដា ឆ្នាំ ២០០៤ មក សកម្មភាពនានារបស់អង្គការ( ស្តារ៉ូ) ត្រូវបានរៀបចំកម្មវិធីឡើងវិញ ដូចខាងក្រោមនេះ

- កម្មវិធីអភិវឌ្ឍន៏សហគមន៏
- កម្មវិធីអភិវឌ្ឍន៏អ្នករើសសំរាម( អេតចាយ)
- កម្មវិធីគ្រប់គ្រងសំណល់រឹង
- កម្មវិធីអប់រំផ្សព្វផ្សាយចល័ត
- កម្មវិធីមណ្ឌលធនធានសហគមន៏
- កម្មវិធីអភិវឌ្ឍន៏ស្ថាប័ន

លទ្ធផល និង ផលប៉ះពាល់នានា របស់កម្មវិធីទាំងអស់នេះត្រូវបានគូសបញ្ជាក់នៅក្នុងទំព័រជាបន្តបន្ទាប់ ។

# CSARO Profile



Community Sanitation And Recycling Organization (CSARO) is a Cambodian Non-Governmental Organization (NGO) established in February 1997 by a group of development workers committed to improving the environment and living conditions of urban poor in Cambodia. CSARO has been a leader in the use of a participatory model to improve conditions in the neglected and unserviced areas where most urban poor live. A special focus of CSARO's work is improving the living and working conditions of the thousands of adult and child waste pickers who eke out a living from Phnom Penh's waste.

## CSARO Vision

Urban communities where residents and waste pickers work together to transform low-income areas into clean, safe and healthy places to live; and where waste pickers work together to improve their social and economic conditions.

## CSARO Mission

To encourage and motivate urban poor people to improve their capacity, their environment, and their social and economic conditions.

## CSARO Goals

1. Assist residents to improve their community infrastructure, solid waste management and hygiene knowledge.
2. Assist waste pickers to better their social and economic conditions through skills development and self-help activities.
3. Improve the community's capacity to develop itself for a sustainable future.
4. Strengthen CSARO staff capacity for greater effectiveness.

## CSARO Program areas

Following the finalization of the new three-year strategic plan (2004-2007) in July 2004, the CSARO activities were reorganized into the following programs:

- Community Development Program
- Waste Picker Development Program
- Solid Waste Management Program
- Mobile Outreach Education Program
- Community Resource Center
- Institutional Development Program

The outputs and impacts of these programs are highlighted on the following pages.

# កម្មវិធីអភិវឌ្ឍន៍សហគមន៍ (CDP)



អង្គការ(ស្ការ៉ូ) ធ្វើការនៅតាមតំបន់ក្រីក្រជាងគេ និង តំបន់ដែលមិនមានសេវាគ្រប់គ្រាន់ នៅក្នុងក្រុងភ្នំពេញ។ នៅក្នុងដំណាក់កាលដំបូង បុគ្គលិកអង្គការ(ស្ការ៉ូ) ធ្វើការកំណត់រកតំបន់សហគមន៍ទីក្រុងដែលមានចំណូលទាប ហើយធ្វើការជាមួយប្រជាពលរដ្ឋសហគមន៍ ក្នុងការរៀបចំការប្រជុំ-ជាច្រើន ដើម្បីកំណត់រកសេចក្តីត្រូវការជាអាទិភាពរបស់ពួកគេ។ សមាជិករបស់គណៈកម្មការអភិវឌ្ឍន៍សហគមន៍ (CDCs) ត្រូវបានជ្រើសរើស និង ទទួលការបណ្តុះបណ្តាលពួកគេអោយចេះធ្វើផែនការ និង អនុវត្តន៍គំរោងអោយមានភាពប្រសើរឡើងរបស់ពួកគេផ្ទាល់។ ក្រុមការងាររបស់អង្គការ(ស្ការូ) ធ្វើការជួយជ្រោមជ្រែងដល់សហគមន៏ អោយចេះអនុវត្តគំរោងរបស់ពួកគេ និង ធ្វើការពិនិត្យតាមដានលើលទ្ធផលនានា។

នៅក្នុងផ្នែកទីមួយ នៃឆ្នាំ ២០០៤, អង្គការ(ស្ការ៉ូ) បានចុះអង្កេតទៅលើ ២៦តំបន់ ដើម្បីកំណត់រកសហគមន៏ទីក្រុងក្រីក្រថ្មីៗ ដែលមានហេដ្ឋារចនាសម្ព័ន្ធទន់ខ្សោយមិនល្អ និង មិនមានសេវាកម្មប្រមូលសំរាម។ នៅក្នុងតំបន់ចំនួន ១១ អង្គការ(ស្ការ៉ូ) បានជួយសហគមន៏ក្នុងការ ធ្វើការវាយតំលៃយ៉ាងរហ័សតាមបែបចូលរួម (PRA) ដែលនៅកន្លែងនោះ ប្រជាពលរដ្ឋធ្វើការជាមួយគ្នា នៅក្នុងការរៀបចំផែនទីសហគមន៏ ដោយមានបញ្ហានានាផ្នែកហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានដៅកំណត់។ បន្ទាប់មក កិច្ចប្រជុំសហគមន៏ ត្រូវបានរៀបចំធ្វើឡើង ដើម្បីពិភាក្សាពីការរកឃើញនានា ហើយជាចុងក្រោយ គណៈកម្មការ(CDCs) ថ្មីចំនួន ១១ ត្រូវបានបង្កើតឡើង ដោយតំណាងអោយប្រជាពលរដ្ឋចំនួន ៨,៨៨៤ នាក់(ចំនួននេះបាននាំអោយចំនួន CDCs ដែលរៀបចំបង្កើតដោយ អង្គការ(ស្ការ៉ូ) បាន កើនឡើងរហូតដល់ ៣៩)។ បន្ទាប់មកសហគមន៏ថ្មីនិមួយៗ ត្រូវធ្វើការជ្រើសរើសឈ្មោះ ហើយ រៀបចំប្រវត្តិរបស់សហគមន៏ ដ៏សង្ខេបមួយដែលមានទិន្នន័យគ្រួសារ, បញ្ហានានាដែលរកឃើញ និង សេចក្តីពិស្តារដ៏ ទៃ ទៀត ។ ការរៀបចំឯកសារទាំងអស់នេះ គឺជាផ្នែកមួយនៃដំណើរការរៀនសូត្រ និង ជួយស្ថាបនា នូវ សាមគ្គីភាពរបស់ប្រជាពលរដ្ឋ។



ការប្រជុំសហគមន៏
Community meeting

អ្នកតំណាងសហគមន៏(CDCs)ជាច្រើន បានចូលរួមយ៉ាងសកម្ម ក្នុងកិច្ចប្រជុំប្រចាំត្រី មាស នៅឯការិយាល័យអង្គការ(ស្ការ៉ូ)។ ជាមធ្យមមានប្រជាពលរដ្ឋចំនួន ៣២ នាក់ បានចូលរួម កិច្ចប្រជុំដ៏រស់រវើកដែលមានរយៈពេលកន្លះថ្ងៃ ទាំងនេះដើម្បីធ្វើការពិភាក្សាទៅលើយុទ្ធសាស្រ្តនានា, កំណត់រកនូវបញ្ហារួម និង ធ្វើការផ្លាស់ប្តូរបទពិសោធន៏គ្នាទៅវិញទៅមក។ ប្រធានបទមួយចំនួន ដែលបាន ពិភា ក្សានាអំឡុងពេលឆ្នាំ ២០០៤ រួមមាន បញ្ហានានាដែលសហគមន៏ទីក្រុងក្រីក្រជួបប្រទះ, របៀបធ្វើការអភិវឌ្ឍន៏ផែនការយុទ្ធសាស្រ្តសហគមន៏, ការប្រមូលផ្តុំការចូលរួមរបស់សហគមន៏, វិធីសាស្រ្តផ្សេងៗគ្នាចំពោះការធ្វើផែនការ សកម្មភាព អោយមានភាពប្រសើរឡើង និង លើរបៀបធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។



ការហ្វឹកហ្វឺនគណៈកម្មការអភិវឌ្ឍន៏សហគមន៏
Community development committee training

# Community Development Program (CDP)





ការរៀបចំសំណើរលើហេដ្ឋារចនាសម្ព័ន្ធ
Preparing infrastructure proposal.



ការតប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាត
Water supply installation.



បង្គន់សាលារៀនដែលបានសាងសង់រួចហើយ
Finished school latrine.

CSARO works in some of the poorest and most underserved areas of Phnom Penh. In the initial stages, CSARO's staff identify low-income areas of the city and help residents to organize meetings to identify their priority needs. Community Development Committees (CDCs) members are elected and trained so that they can plan and implement their own improvement projects. CSARO teams assist the communities to implement their projects and monitor the results.

In the first part of 2004, CSARO surveyed 26 areas to identify new urban poor communities with weak infrastructure and lacking waste collection services. In 11 areas, CSARO assisted the community to undertake a participatory rapid appraisal (PRA), where residents work together in the preparation of community maps with infrastructure problems identified. Next, community meetings were held to discuss the findings and eventually 11 new CDCs were formed representing 8,884 residents (this brings the total number of CDCs organized by CSARO to 39). Each new CDC must then chose a name and prepare a community profile containing a brief community history, data on the households, problems identified and other details . The preparation of these documents are part of the learning process and help to build solidarity among residents.

Representatives from all of the active CDCs participated in quarterly meetings at the CSARO office. On average 32 people attended these lively, half-day meetings to discuss strategies, identify common issues and exchange experiences. Some of the topics discussed during 2004 included problems facing urban poor communities, how to develop a community strategic plan, mobilizing community participation, different approaches to planning improvement activities, and how to communicate with local authorities.

# កម្មវិធីអភិវឌ្ឍន៍សហគមន៍ (CDP)



ដើម្បីពង្រឹងសមត្ថភាពបន្ថែមទៀតដល់ សមាជិកគណៈកម្មការអភិវឌ្ឍន៍សហគមន៍ អង្គការ(ស្ការ៉ូ) បានផ្តល់ការបណ្តុះបណ្តាលរយៈពេល ពីរថ្ងៃកន្លះនៅក្នុង ខែកុម្ភៈ ដែលមានអ្នកចូលរួមចំនួន ៣០ នាក់ លើជំនាញភាពជាអ្នកដឹកនាំ, ការរៀបចំសហគមន៍, ការដោះស្រាយបញ្ហាតាមលក្ខណៈចូលរួម និង យុទ្ធសាស្ត្រនានា សំរាប់ធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

ដើម្បីធ្វើអោយស្ថានភាពរស់នៅក្នុងសហគមន៍មានភាពប្រសើរឡើង នៅក្នុងឆ្នាំ ២០០៤ អង្គការ(ស្ការ៉ូ) បានសំរបសំរួល សហគមន៍ CDCs ចំនួន ៥ ធ្វើការអនុវត្តន៍សកម្មភាពអោយមានភាពប្រសើរឡើង ចំនួន ៧គំរោង ។ គំរោងទាំងនេះបានផ្តល់ផលប្រយោជដល់ប្រជាពលរដ្ឋចំនួនច្រើនជាង ១២២២ នាក់។ ការសំរបសំរួលរបស់អង្គការ (ស្ការ៉ូ) រួមមាន ការបណ្តុះបណ្តាល, ការរៀបចំសហគមន៏ដែលបានរៀបរាប់ខាងលើ និង ជំនួយ-បច្ចេកទេសលើការធ្វើផែនការ និង ការអនុវត្តន៏គំរោង។ អង្គការ(ស្ការ៉ូ) ក៏បានផ្តល់សម្ភារៈសំរាប់ការអនុវត្តន៏គំរោងផងដែរ។ នាអំឡុងឆ្នាំ ២០០៤, សហគមន៍នានាបានប្រមូលបដិភាគជាមធ្យម ចំនួន ៥៨ %នៃការចំណាយរបស់គំរោង ហើយអង្គការ(ស្ការ៉ូ) បានផ្តល់បដិភាគជាមធ្យមចំនួន ៤២ % រួម-ទាំងសំភារៈ សំរាប់សាងសង់។

សេចក្តីសង្ខេបសកម្មភាពដែលបានធ្វើនៅក្នុងឆ្នាំ ២០០៤ រួមមានៈ

- គំរោងតបណ្តាញលូប្រព័ន្ធបង្ហូរទឹក ចំនួន ៣គំរោង ដែលមានបំពង់លូបេតុងប្រវែង ២៥៣ ម៉ែត្រ ត្រូវបានតរួចដោយផ្តល់អត្ថប្រយោជន៏ដល់ប្រជាពលរដ្ឋចំនួន ៤៧១ នាក់ ។
- គំរោងចាក់សាបតាមបណ្តោយផ្លូវច្រកតូចៗចំនួន ២កន្លែង ដែលមានទំហំ ៤០៥ ម៉ែត្រក្រលា និង ផ្តល់អត្ថប្រយោជន៏ដល់ប្រជាពលរដ្ឋចំនួន ១៤៨ នាក់។
- គំរោងតបណ្តាញប្រពន្ធ័ទឹកស្អាតចំនួន១គំរោង ដែលដាក់បំពង់ទុយោទឹកប្រវែង ២៧០ ម៉ែត្រ ហើយ បានតភ្ជាប់សំរាប់ប្រជាជន ២៧ គ្រួសារ និងផ្តល់អត្ថប្រយោជន៏ ដល់ប្រជាជនចំនួន ២០៨ នាក់។
- គំរោងបង្គន់អនាម័យនៅសាលារៀន ចំនួន ១ខ្នងមាន ៤ បន្ទប់បានសាងសង់ ហើ-យផ្តល់ផលប្រយោជន៏ដល់ លោកគ្រូអ្នកគ្រូ និង សិស្សានុសិស្ស ចំនួន ៦៥៨ នាក់។



ការប្រជុំប្រចាំត្រីមាសCDCs
CDCs quarterly meeting

# Community Development Program (CDP)





ការប្រជុំធ្វើគំរោងផែនការ
Project planning meeting.



ការតបណ្តាញប្រព័ន្ធទឹកស្អាត

Installation of new water supply.



កុមារនាំគ្នាលេងលើផ្លូវច្រកតូចដែលធ្វើរួចហើយ

Children play on improved alley

To further strengthen the capacity of CDC members, CSARO provided a two and a half day training in February for 30 participants on leadership skills, community organizing, participatory problem solving and strategies for communicating with local authorities.

To improve the living conditions in the communities, CSARO assisted 5 CDCs to undertake 7 improvement projects during 2004. These projects affected more than 1222 residents. CSARO assistance included the training and organizational support mentioned above, and technical assistance in planning and implementing the project. CSARO also provides material support for project implementation. During 2004, communities mobilized an average of 58% of project costs, while CSARO provided an average of 42% , mainly for construction materials.

A summary of projects completed in 2004 includes:

- Three sewer and drainage projects with 253 meters of concrete pipes installed benefiting 471 residents.
- Two alleyway-paving projects with 405 square meters of paving benefiting 148 residents.
- One water supply project with 270 meters of pipe and 27 household connections installed benefiting 208 residents.
- One school latrine project with four stalls built, benefiting 658 students.

# កម្មវិធីអប់រំផ្សព្វផ្សាយចល័ត (MOE)



សំណង់សហគមន៍អ្នកក្រីក្របានកើនឡើងនៅក្នុងទីក្រុង ហើយ ប្រជាពលរដ្ឋអ្នកក្រីក្រជាច្រើនខ្វះការយល់ដឹងអំពីការបោះចោលកាកសំណល់អោយបានត្រឹមត្រូវ និង អនាម័យ។ មនុស្សពេញវ័យ និង កុមារ អ្នករើសសំរាម(អេតចាយ)ជាច្រើននាក់បានដើររើសសំនល់(អេតចាយ)តាមផ្លូវនានាក្នុង ទីក្រុង ដោយមានពេលវេលា និង ឱកាស បន្តិចបន្តួចចំពោះការអប់រំ។ កម្មវិធីអប់រំផ្សព្វផ្សាយចលត័ (MOE) របស់អង្គការ(ស្ការ៉ូ) បាននាំមកនូវ សកម្មភាពបណ្តុះ បណ្តាល និង ផ្សព្វផ្សាយយល់ដឹងតាមដងផ្លូវនានាទៅដល់អ្នករើសសំរាមអេតចាយ និង សហគមន៍ដែលមានអ្នកក្រីក្ររស់នៅក្នុងទីក្រុង។

**ការអប់រំដល់អ្នករើសសំរាម(អេតចាយ)**

ឆ្នាំ ២០០៤ បានបង្ហាញអោយឃើញថាកម្មវិធីអប់រំតាមចិញ្ចើមផ្លូវរបស់អង្គការ(ស្ការ៉ូ) បានពង្រីកប្រកបដោយលក្ខណៈថ្មៃប្រឌិត ។ ដោយមាន-គ្រូបង្ហាត់ចំនួន២ក្រុម និង សកម្មភាពពេលថ្ងៃ នឹង ពេលយប់, បុគ្គលិកកម្មវិធីអប់រំផ្សព្វផ្សាយចល័ត(MOE) បានផ្តល់វគ្គអប់រំក្រៅប្រព័ន្ធ សរុបទាំងអស់ចំនួន ៩៩៩ វគ្គ នៅក្នុងឆ្នាំ ២០០៤ (ជាមធ្យមមាន ៣០វគ្គ ក្នុងមួយសប្តាហ៍)។ ការចូលរួមបានកើនឡើងពី ៤៥០ ទៅ ៧៦៨នាក់ នៃអ្នករើសសំរាម (អេតចាយ) ហើយចំនួននៃចំនុចណាត់ជួបនៅតាមចិញ្ចើមផ្លូវ បានកើនឡើងពី ១៥ ទៅ ១៧ កន្លែង (ទីកន្លែងបង្រៀន ) ។ នៅក្នុងខែ សីហា អង្គការ(ស្ការ៉ូ) បានទិញរថយន្តក្រុងមួយដែលមាន ២៥ កៅអី ហើយបានធ្វើការផ្លាស់ប្តូរ អោយទៅជាថ្នាក់រៀនចល័តមួយ ដែលបំពាក់ទៅដោយរនាំងបាំងថ្ងៃដែលអាច បត់បានសំរាប់ការ បង្រៀន នៅខាងក្រៅ ឡាននាពេលរដូវប្រាំង ហើយកៅអីទាំងអស់ត្រូវបានរើចេញ ដើម្បីធ្វើជាថ្នាក់រៀនខាងក្នុង មួយ សំរាប់ប្រើប្រាស់ អំឡុងពេលនៃរដូវវស្សា។ អង្គការ(ស្ការ៉ូ) បានសំរបសំរួល កុមារមួយចំនួនពី កម្មវិធីអប់រំក្រៅប្រព័ន្ធ ចូលទៅក្នុងប្រព័ន្ធសាលារៀនធម្មតា ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការផ្លាស់ប្តូរនេះ គឺជាការពិបាក ហើយការដើររើស(អេតចាយ)នៅតាមផ្លូវជាការចាំបាច់មួយ ចំពោះកុមារភាគច្រើនត្រូវការទ្រទ្រង់ជីវិតរបស់ពួកគេ។



កម្មវិធីរថយន្តក្រុងMOE អប់រំតាមចិញ្ចើមថ្នល់
Curb-side education with MOE bus.



ការញុំាអាហារសំរ៉ន់បន្ទាប់ពីវគ្គសិក្សា
Snack after curb-side session

កម្មវិធីអប់រំផ្សព្វផ្សាយចល័ត (MOE) បានបង្កើតមេរៀនបណ្តុះបណ្តាលចំនួន ៣៣មេរៀន លើប្រធានបទដូចជា *របៀបអាន និង របៀបសរសេរ, អនាម័យផ្ទាល់ខ្លួន, សំណល់គ្រោះថ្នាក់, សិទ្ធិកុមារ និង ការការពារបរិស្ថាន*។ មេរៀននិមួយៗ បានប្រើប្រាស់លើវិធីសាស្រ្តក្នុងការបង្រៀនខុសៗគ្នា ដូចជា ចំរៀង, ការដើរតួសំដែងរឿង, ការពិភាក្សាជាក្រុម និង ការសំដែងសិល្បៈ។ ការតាមដានពិនិត្យមើលលើភាពរីកចំរើនរបស់សិស្ស និង ធ្វើអោយកម្មវិធីមានលក្ខណៈឆ្លើយតប, ប្រព័ន្ធវាយតំលៃលើចំណេះដឹងរបស់សិស្ស ដែលមានបីកំរិត ថ្មីមួយ ត្រូវបានសាកល្បងធ្វើឡើងនៅឆ្នាំ ២០០៤។ ប្រព័ន្ធពិនិត្យតាមដាននេះ បានទទួលជោគជ័យ យ៉ាងខ្លាំង ហើយនឹងត្រូវបានធ្វើការពង្រីកបន្ថែមនៅក្នុងឆ្នាំ ២០០៥ ។

# Mobile  Outreach Education Program (MOE)





កុមាររើសសំរាម(អេតចាយ)លាងដៃ
Waste pickers wash hands.



ការថែរក្សាបឋមពីកុមារទៅកុមារ
Child to child first-aid care.



ទិវាកុមារអន្តរជាតិ
Children’s Day activities.

Growing up in the city’s slums and resettlement communities, many residents lack awareness about proper waste disposal and sanitation. Working on the city’s streets, waste picker children and adults have little time and few opportunities for education. CSARO’s MOE program brings training and awareness activities on to the streets where the waste pickers work and into the low-income communities where the city’s poor live.

## Waste Picker Education

2004 saw the expansion of CSARO’s innovative curb-side education program. With two instructor teams, and day and evening activities, MOE staff conducted a total of 999 non-formal education sessions in 2004 (an average of 30 sessions per week). Participation increased from 450 to 768 waste pickers and the number of curbside contact points (where sessions take place) increased from 15 to 17 sites during the year. In August, CSARO purchased a 25-seat bus and converted it into a mobile classroom equipped with a large folding sunshade for outdoor sessions during the hot season, and all the seats removed to make an indoor classroom for use during the rainy season. CSARO has helped some children from the non-formal education program integrate into the normal school system, however the transition is difficult, and work on the street is a necessity of life for many.

The MOE program developed 33 new training modules on subjects including reading and writing, personal hygiene, hazardous materials in waste, children’s rights and protecting the environment. Each module uses a variety of learning methods including songs, role plays, group discussions and art. To improve monitoring of student progress and make the program more responsive, a new 3-level system of assessing student knowledge was piloted in 2004. The monitoring system has been quite successful and will be expanded in 2005.

# កម្មវិធីអប់រំផ្សព្វផ្សាយចល័ត (MOE)



បន្ទាប់ពីវគ្គបង្រៀនក្រៅប្រព័ន្ធនិមួយៗ, សំភារៈថែរក្សាបឋម ត្រូវបានយកចេញមក ហើយកុមារដែលមានអាយុច្រើនជាង ជួយកុមារដែលមានអាយុតិច ក្នុងការលាងសំអាតស្បែករលាត់ និង មុខរបួស ដែលរងគ្រោះអំឡុងពេលដើររើស(អេតចាយ)របស់ពួកគេ នៅតាមផ្លូវ។ អ្នករើសសំរាម(អេតចាយ) ដែលមាន របួស និង ជំងឺធ្ងន់ធ្ងរ ត្រូវបានយកទៅគ្លីនិកនៅក្នុងទីក្រុង ដែលបានទទួលការព្យាបាលដោយមិនគិតថ្លៃ ឬ តំលៃទាប។ នៅឆ្នាំ ២០០៤ មានកុមារចំនួន ៦៧៣ នាក់ និង មនុស្សពេញវ័យ ៤៧ នាក់ បានទទួលការថែរក្សាជំនួយបឋម ហើយ កុមារ ១៧ នាក់ និង មនុស្សពេញវ័យ ៧ នាក់ ត្រូវបានបញ្ជូន ទៅព្យាបាលនៅគ្លីនិកនានា ដែលមានរបួសក្លាយ រហូតដល់ជំងឺគ្រុនក្តៅខ្លាំង។

ការលើកកំពស់យល់ដឹង និង ដោះស្រាយសេចក្តីត្រូវការពិសេស របស់ស្ត្រីភេទអ្នករើសសំរាម(អេតចាយ), បុគ្គលិកអង្គការ(ស្ការ៉ូ) បានរៀបចំការពិភាក្សាជាក្រុម និង ពិគ្រោះយោបល់ជាមួយស្ត្រី ដែលមានចំនួន ៣២ នាក់ និង កុមារីចំនួន ២១ នាក់។ ការផ្តល់ពិគ្រោះយោបល់ពីបញ្ហា សុខភាពបន្តពូជ, ផែនការគ្រួសារ, ការជួញដូរស្ត្រីភេទ, ការរំលោភបំពានផ្លូវភេទ និង អំពើហឹង្សាក្នុងគ្រួសារ។ មានស្ត្រីចំនួន ១០ នាក់ និង ក្មេងស្រី ចំនួន ៥ នាក់ត្រូវបានបញ្ជូ នទៅមជ្ឈមណ្ឌលសុខភាពស្ត្រីមួយ សំរាប់ការពិគ្រោះយោបល់។

ការផ្តល់ឱកាសមួយសំរាប់សិស្សក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធបានចាកចេញពីទីក្រុង, ដើម្បីទទួលបទពិសោធន៍ថ្មី និង រៀនសូត្រ អំពីធម្មជាតិបរិស្ថាន, កម្មវិធីអប់រំផ្សព្វផ្សាយចល័ត (MOE) បានរៀបចំទស្សនៈកិច្ចមួយមានរយៈពេលមួយថ្ងៃទៅឆ្នេរសមុទ្រក្នុងខេត្តកំពត។ អ្នករើសសំរាមពេញវ័យចំនួន៤នាក់ និង កុមារ៤៥ នាក់ បានចូលរួមជាមួយបុគ្គលិកកម្មវិធី ហើយក្រុមនេះបានសិក្សាពីរុក្ខជាតិ និង សត្វ។ សកម្មភាពដ៏ប្រសើរមួយផ្សេងទៀតបានរៀបចំសំរាប់កុមាររើស(អេតចាយ)ចំនួន៤៥ និង មនុស្សពេញវ័យចំនួន ៥នាក់ ចូលរួមទិវាកុមារអន្តរជាតិ នៅទីក្រុងភ្នំពេញ នា ថ្ងៃទី ១ ខែមិថុនា។

## ការអប់រំដល់អ្នកសហគមន៍

បុគ្គលិកក្នុងកម្មវិធីអប់រំផ្សព្វផ្សាយចល័ត(MOE)បានធ្វើការជាមួយអ្នកស្ម័គ្រចិត្តសហគមន៍ ចំនួន ១២តំបន់ ហើយបានរៀបចំបណ្តុះបណ្តាលដល់អ្នកសហគមន៍ ចំនួន ៥៩វគ្គ (ជាសរុបមាន ១១៨ ម៉ោង)។ វគ្គសិក្សាដ៏រស់រវើកទាំងនេះ បានប្រើប្រាស់ សំណួរ និង ចំលើយ, ការសំដែងរឿងខ្លីៗ, និទាន រឿង, ចំរៀង និង ការពិភាក្សាជាក្រុម ដើម្បីទាក់ទាញ នូវការចាប់អារម្មណ៍ ពីសំណាក់ប្រជាពលរដ្ឋ នៅក្នុងសហគមន៍អោយយល់ដឹងពីការបែងចែកសំរាម, ការប្រមូលសំរាម, សារៈសំខាន់អនាម័យបរិស្ថាន និង ទឹកស្អាតនៅក្នុងសហគមន៍។ ដើម្បីពង្រឹងនូវ សារពតិមានទាំងនេះ អ្នកចូលរួមទាំងអស់បានទទួលនូវឯកសារ, ប័ណ្ណផ្សព្វផ្សាយ និង ប្រក្រតីទិន។



ការថែទាំជំនួយបឋម
First-aid care.

# Mobile Outreach Education Program (MOE)



After each non-formal education session, first-aid kits are brought out and the older children help the younger kids to clean scrapes and open wounds suffered during their work on the streets. Waste pickers with more serious injuries and illnesses are brought to an urban clinic which has agreed to provide free or low cost treatment. During 2004, 673 children and 47 adults received first aid treatment and 17 children and 7 adults were referred to the clinics for problems ranging from infected wounds to high fever.

To raise awareness and address the special needs of female waste pickers, CSARO staff organized group discussions and counseling sessions with 32 women and 21 girls. Topics included reproductive health, family planning, human trafficking, sexual abuse and domestic violence. 10 women and 5 girls were referred to a women's health center for consultation.



វគ្គសិក្សាតាមចិញ្ចើមថ្នល់នាពេលយប់
Nighttime curb-side session



វគ្គសិក្សាអប់រំសហគមន៍
Community education session

To give students of the non-formal education program an opportunity to get out of the city, experience nature and learn about a new environment, the MOE program organized a one-day field visit to the seaside in Kampot Province. Participants included 45 of the most active students and 4 adults. The group studied flora and fauna with program staff. Another enrichment activity assisted 45 waste picker children and 5 adults to participate in International Children's Day celebrations in Phnom Penh on the first of June.

**Community Education**

Staff from the MOE program worked with community volunteers in 12 areas to organize 59 community-training sessions (about 118 hours in total). These lively sessions used question and answer, role play, stories, songs and group discussions to capture the interest of residents and at the same time educate them on subjects including waste separation, community waste collection and the importance of clean water. To reinforce the messages, participants received handouts, posters and calendars.

# កម្មវិធីអភិវឌ្ឍន៍អ្នករើសសំរាមអេតចាយ (WPD)



កម្មវិធីអភិវឌ្ឍន៍អ្នករើសសំរាម(អេតចាយ)(WPD) ត្រូវបានរៀបចំឡើងដើម្បីធ្វើការលើកតំកើងការអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ច របស់មនុស្សពេញវ័យ និង កុមារអ្នករើសសំរាម(អេតចាយ) តាមរយៈសកម្មភាពនានា នៅមណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម(អេតចាយ)(WPDC) របស់អង្គការ(ស្ការ៉ូ)។ មណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម(អេតចាយ)(WPDC)មានទីតាំងនៅក្នុងសាលាបឋមសិក្សារដ្ឋទូលស្លែង ដែល-ស្ថិតនៅក្នុងខ័ណ្ឌចំការមន ក្រុងភ្នំពេញ ហើយនៅលើផ្លូវដែលមានភាពអ៊ូរអរ។ អ្នករើសសំរាម(អេតចាយ)នានាដែលធ្វើដំណើរឆ្លងកាត់ទីនោះបានឈប់ដើម្បីប្រើប្រាស់បង្គន់អនាម័យ, ហូបទឹក, ងូតទឹក ឬក៏ប្រើប្រាស់កន្លែងទំនេរ ដើម្បីបែងចែក និង រៀបចំសំភារៈអេតចាយទៅតាមប្រភេទ ។ ការទំនាក់ទំនងយ៉ាងល្អទាំងនេះ ធ្វើអោយអ្នករើសសំរាម(អេតចាយ)ជាច្រើន មានការពាក់ព័ន្ធសកម្មភាពនានានៅក្នុងមណ្ឌល។ សំរាប់កុមាររើសសំរាម(អេតចាយ)មានឱកាសចូលរួមសកម្មភាពអប់រំក្រៅប្រពន្ធ័, ល្បែងបណ្តុះគំនិតនានា, ការបណ្តុះបណ្តាលជំនាញ, ការពិគ្រោះយោបល់ និង សកម្មភាពជាច្រើនផ្សេងៗទៀត។ សំរាប់មនុស្សពេញវ័យ អ្នក រើសសំរាម(អេតចាយ)ចូលរួមក្រុមជួយខ្លួនឯង ទទួលការបណ្តុះបណ្តាលជំនាញ បែ-ងចែកសំរាម, ការ ប្រមូលសំរាបបឋម, ការធ្វើជីកំប៉ុស្ត, និង ជំនាញកា-រកែច្នៃសំណល់ផ្សេងៗទៀតដែលអាចប្រើប្រាស់បាន ។ នាអំឡុងឆ្នាំ ២០០៤, មានអ្នករ-ើសសំរាម(អេតចាយ)បានចូលទៅប្រើប្រាស់មណ្ឌល(WPDC)កើនឡើង ជាមធ្យមពីចំនួន៣៥នាក់នៅក្នុង ខែ មករា ទៅ ៦០នាក់ក្នុងមួយថ្ងៃៗនាបំណាច់ឆ្នាំ ដែលមានចំនួនសរុបទាំងអស់១២,៨០៧ នៅក្នុង ឆ្នាំ២០០៤។



ការអប់រំក្រៅប្រព័ន្ធនៅមណ្ឌល WPDC
Non-formal education at WPDC.

នៅមណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាមអេតចាយ (WPDC) មានសកម្មភាពពិគ្រោះយោបល់ និង ជំនួយថែរក្សាសុខភាពបឋម។ មានកុមារចំនួន ៤៩ នាក់ និង មនុស្សពេញវ័យចំនួន ៦៦ នាក់ បានទទួល ជំនួយថែរក្សាសុខភាពបឋម។ មានមនុស្សពេញវ័យចំនួន ២១នាក់ ហើយនិង កុមារចំនួន ៥៧ នាក់ បាន ចូលរួមពិភាក្សាជាក្រុម ទៅលើ បញ្ហា សិល្បៈធមិ, សុខភាពបន្តពូជ, ការជួញដូរមនុស្ស, ការគំរាមគំហែង, ការរំលោភបំពានផ្លូវភេទ, ការរំលោភបំពានដែលចេញពីការប្រើប្រាស់គ្រឿងញៀន, អំពើហឹង្សាក្នុងគ្រួសារ និង សុខភាពផ្លូវចិត្ត។

ក្នុងការលើកតំកើងការអភិវឌ្ឍផ្នែកសង្គម និង សេដ្ឋកិច្ច, បុគ្គលិករបស់មណ្ឌល (WPDC) បានធ្វើការសំរបសំរួលជាមួយមនុស្សពេញវ័យអ្នករើសសំរាម(អេតចាយ) ដើម្បីបង្កើតជាសមាជិកក្រុមជួយខ្លួនឯង (SHGs)។ ក្នុងអំឡុងរយៈពេលនេះ មានក្រុមថ្មីចំនួន ៦ ត្រូវបានបង្កើតឡើងដោយ ក្រុមនិមួយៗមានសមាជិកចំនួន ៧ នាក់។ ក្រុមនិមួយៗ ធ្វើការប្រជុំ ដើម្បីជ្រើសរើសឈ្មោះសំរាប់ក្រុម និង ដើម្បីរៀបចំឡើងនូវគោលបំណងរបស់ក្រុម។ សមាជិកក្រុមជួយខ្លួនឯងជាច្រើន បានទទួលការបណ្តុះបណ្តាលជំនាញ ពីអង្គការ(ស្ការ៉ូ) លើការរៀបចំក្រុម, ភាពជាអ្នកដឹកនាំ, និង លើជំនាញផ្នែកកែច្នៃ ដូចជាការបែងចែកសំរាមដាច់ពីគ្នា, ការផលិតជីកំប៉ុស្ត និង ការផលិតវត្ថុហត្ថកម្មពីសំភារៈកែច្នៃ។ អ្នករើស



កុមារប្រើប្រាស់បណ្ណាល័យក្នុងមណ្ឌលWPDC
Children use WPDC library.

# Waste Picker Development Program (WPD)



